# សេចក្តីជូនដំណឹង
# ស្តីពី
# ការពន្យារពេលបន្ថែម ចំពោះការផ្សព្វផ្សាយរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩
# របស់ធនាគារវឌ្ឍនៈអាស៊ី ចំកាត់

ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ (ធនាគារ ABA) សូមជម្រាបជូនដំណឹងដល់វិនិយោគិន និងសាធារណជន មេត្តាជ្រាបថា៖ យោងតាមប្រកាសលេខ ០០៧ / ១៨ គ.ម.ក / ប្រ.ក. ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ធនាគារ ABA មានកាតព្វកិច្ចត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩ ជូនគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក)។

កាលពីថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ធនាគារ ABA បានធ្វើការជូនដំណឹងអំពីការពន្យារពេលផ្សព្វផ្សាយរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០ ដោយមូលហេតុធនាគារត្រូវការពេលវេលាដើម្បីពិនិត្យបញ្ចប់តួលេខហិរញ្ញវត្ថុសំខាន់ៗមួយចំនួនពីភាគីពាក់ព័ន្ធ។ ដោយហេតុការិយបរិច្ឆេទជម្រាបជូនខាងលើបានឈានមកដល់ ធនាគារ ABA និងក្រុមហ៊ុនសវនកម្មនៅត្រូវការពេលវេលាបន្ថែមទៀត ក្នុងការបញ្ចប់ការត្រួតពិនិត្យរបាយការណ៍ ដើម្បីធានាថារបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩ និងរបាយការណ៍ប្រចាំឆ្នាំ២០១៩ មានតួលេខដូចគ្នា។

ដូចនេះធនាគារ ABA សូមពន្យារពេលផ្សព្វផ្សាយរបាយការណ៍ប្រចាំត្រីមាសទី៤ ឆ្នាំ២០១៩ ជូន គ.ម.ក. រហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០។

ថ្ងៃអង្គារ ២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា គ.ស.២០២០
**ធនាគារវឌ្ឍនៈអាស៊ី ចំកាត់**

**Head Office**
No. 141, 146, 148 and 148 ABCD Preah Sihanouk Blvd,
and No. 15 and 153 ABC, Street 278, Sangkat Boeung Keng Kang 1,
Khan Boeung Keng Kang, Phnom Penh, Kingdom of Cambodia
Tel: (+855) 23 225 333
info@ababank.com
www.ababank.com
Fax: (+855) 23 216 333
P.O. Box: 2277
SWIFT: ABAAKHPP